
ម្លិះរួត


ម្លិះលា


កុលាប


ច័ន្ទ


ស្បៃរឿង


ឈូករ័ត្ន


ចំប៉ី


ចំប៉ា


ចេកទេស


ចេកទុំ


មាលតី


នួនស្រី


ទំហ៊ូ


ម៉ោងដប់

# ផ្កាក្នុងឧទ្យាន

គយគន់ឧទ្យានមានបុស្បា
រីករាយត្រៀបត្រាសង្ហាពេក
ម្លិះរួតម្លិះលាល្អអនេក
កុលាបគួរត្រេកត្រឹបស្នេហា។

ច័ន្ទក្រៀកគូនឹងស្បៃរឿង
ឈូករ័ត្នពណ៌លឿងមិនឯកា
ចំប៉ីចំពិតជិតចំប៉ា
ចេកទេសនុ៎ះណា៎ក្បែរចេកទុំ។

មាលតីនួនស្រីស្រស់ចំប្រប់
ទំហ៊ូម៉ោងដប់ដុះជាក្រុម
រីក្នុងគង្គាមានបទុម
ដុះជុំលាយឡំនឹងសេតុប្បល។

ក្រដាសស្គុះស្គាយជាយរបង
ក្រៀកកិតស្និទ្ធស្នងនឹងរំយោល
មានសក្រហមមានញីឈ្មោល
រំដួលមិនទោលផ្កាពេញមែក។




បទុម



ក្រដាស់



រំយោលឈ្មោល



រំយោលញី



រំដួល



សិរមាន់



អញ្ជ័ន



ណាគ្រី



ចេកមាស



សុរភី



អង្គរជុំ



ផ្កាកែវ

សិរមាន់អញ្ជ័នព័ន្ធណាគ្រី
ចេកមាសសុរភីល្អចម្លែក
អង្គរជុំជាតិមិនឃ្លាតបែក
ផ្កាកែវរីកចែកចាយគន្ធា។

ឃីហ៊ុបឃីស៊ុនល្អគន់ពិត
ឃិតថៅប្រផិតជិតក្តាំងងា
កំភ្លឹងប្រឹងរីកក្បែរមន្ទារ
យុថ្កាវារករកអង្គាបុស្ស។

ក្នុងសួនម្លួនមានផ្កាច្រើនម្លឹង
ម្តេចចិត្តសម្រឹងមិនស្រណោះ
ផ្កាឈរផ្កាវារមានចម្រុះ
ចិត្តហោះរកផ្កាក្រៅឧទ្យាន។

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**



ឃីហ៊ុប



ឃីស៊ុន



ឃិតថៅ



ក្តាំងងា



កំភ្លឹង



មន្ទារ



យុថ្កា



អង្គាបុស្ស